សំណើប្រជាមតិ

# 33 ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ តំលៃបុព្វលាភរ៉ាប់រងផ្អែកលើប្រវត្តិការរ៉ាបរងរបស់អ្នកបើកបរ។ ច្បាប់ផ្ដើមប្រជាសិទ្ធិ។

**ចំណងជើងជាផ្លូវការ និងសេចក្ដីសង្ខេប** **រៀបចំដោយអគ្គមេធាវី**

## ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ តំលៃបុព្វលាភរ៉ាប់រងផ្អែកលើប្រវត្តិការរ៉ាបរងរបស់អ្នកបើកបរ។ ច្បាប់ផ្ដើមប្រជាសិទ្ធិ។

- ប្ដូរច្បាប់បច្ចុប្បន្ន ដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រងកំណត់តម្លៃ ដោយផ្អែកលើ ថាតើអ្នកបើកបរនោះពីមុនមកមានធានារ៉ាប់រងយានយន្តជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយដែរ ឬទេ។
- អនុញ្ញាតឲ្យក្រុមហ៊ុន ផ្ដល់ការបញ្ចុះតម្លៃជាសមាមាត្រដល់អ្នកបើកបរ ដែលមានប្រវត្តិខ្លះៗនៃការគ្របដណ្ដប់ខាងការធានារ៉ាប់រងពីមុនមក។
- នឹងអនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រង បង្កើនថ្លៃធានារ៉ាប់រង ចំពោះអ្នកបើកបរទាំងឡាយណាដែលមិនបានរក្សាការគ្របដណ្ដប់ជាបន្ត។
- ចាត់ទុកអ្នកបើកបរជាមួយនឹងរយៈកាលកន្លងទៅ ដែលបានគ្របដណ្ដប់ជាបន្ត ប្រសិនបើរយៈកាលកន្លងទៅ បណ្ដាលមកពីសេវាកងទ័ព ឬប្រសិនបើរយៈកាលកន្លងទៅតិចជាង 90 ថ្ងៃ។

33 **សេចក្ដីសង្ខេបនៃការប៉ាន់ស្មានរបស់អ្នកវិភាគអង្គនិតិបញ្ញត្តិនៃផលប៉ះពាល់សារពើពន្ធលើចំណូលសុទ្ធរបស់រដ្ឋ និងមូលដ្ឋាន**

- ប្រហែលគ្មានឥទ្ធពលសារពើពន្ធក្នុងប្រាក់ចំណូលពន្ធបុព្វលាភធានារ៉ាប់រងរបស់រដ្ឋ។

---

### ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

## សាវតារ

ការធានារ៉ាប់រងយានយន្ត គឺជាប្រភេទការធានារ៉ាប់រងដ៏សំខាន់ ដែលជាវដោយពលរដ្ឋនៅរដ្ឋកាលីហ្វ័រញ៉ា។ វាមានចំនួនប្រហែល $21 ពាន់លានដុល្លារ (40 ភាគរយ) នៃបុព្វលាភទាំងអស់ ដែលប្រមូលដោយអ្នកធានារ៉ាប់រងនៅរដ្ឋកាលីហ្វ័រញ៉ាក្នុងឆ្នាំ 2011។

***និយ័តកម្មរដ្ឋស្ដីពីការធានារ៉ាប់រងយានយន្ត។*** នៅឆ្នាំ 1988 អ្នកបោះឆ្នោតនៅរដ្ឋកាលីហ្វ័រញ៉ាបានអនុម័តសំណើប្រជាមតិលេខ 103 ដែលតម្រូវឲ្យស្នងការធានារ៉ាប់រងពិនិត្យឡើងវិញ និងឯកភាពលើការផ្លាស់ប្ដូរអត្រាសម្រាប់ប្រភេទនៃការធានារ៉ាប់រងមួយចំនួន រួមទាំងការធានារ៉ាប់រងយានយន្ត មុននឹងការផ្លាស់ប្ដូរអត្រាទាំងនោះអាចចូលជាធរមាន។ សំណើប្រជាមតិលេខ 103 ក៏តម្រូវឲ្យកំណត់អត្រា និងបុព្វលាភសម្រាប់គោលការណ៍ធានារ៉ាប់រងយានយន្ត ដោយអនុវត្តកត្តាកំណត់លំដាប់ខាងក្រោមក្នុងការកាត់បន្ថយលំដាប់នៃភាពសំខាន់៖ (1) កំណត់ត្រាសុវត្ថិភាពបើកបរដែលបានធានារ៉ាប់រង (2) ចំនួនម៉ៃដែលពួកគេបើកបរក្នុងមួយឆ្នាំ និង (3) ចំនួនឆ្នាំដែលពួកគេបានបើកបរផងដែរ។

ស្នងការធានារ៉ាប់រងអាចអនុម័តកត្តាកំណត់លំដាប់បន្ថែមទៀតឲ្យចូលជាធរមាន ដើម្បីកំណត់អំពីអត្រា និងបុព្វលាភយានយន្ត។ បច្ចុប្បន្ននេះជម្រើសកត្តាកំណត់លំដាប់ចំនួន16 អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងទាំងនេះ។ ឧទាហរណ៍ក្រុមហ៊ុនធានារ៉ាប់រងអាចផ្ដល់ការបញ្ចុះតម្លៃជូនបុគ្គលទាំងឡាយ ទៅលើការរក្សាការគ្របដណ្ដប់ ជាមួយនឹងពួកគេ។ ទោះបីជាយ៉ាងណា ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបានហាមឃាត់ពីការផ្ដល់ការបញ្ចុះតម្លៃប្រភេទនេះជូនអតិថិជនថ្មី ដែលបានប្ដូរមកពីអ្នកធានារ៉ាប់រងដទៃទៀត។

***ពន្ធបុព្វលាភធានារ៉ាប់រង។*** ក្រុមហ៊ុនធានារ៉ាប់រង ដែលធ្វើអាជីវកម្មនៅកាលីហ្វ័រញ៉ា បច្ចុប្បន្ននេះ បង់ពន្ធបុព្វលាភធានារ៉ាប់រង ជំនួសឲ្យពន្ធប្រាក់ចំណូលសាជីវកម្មរដ្ឋ។ ពន្ធបុព្វលាភគឺ ផ្អែកទៅលើចំនួននៃបុព្វលាភធានារ៉ាប់រងដុល ដែលរកបាននៅក្នុងរដ្ឋមួយឆ្នាំៗ សម្រាប់ការធានារ៉ាប់រងយានយន្តក៏ដូចជាសម្រាប់ការគ្របដណ្ដប់ធានារ៉ាប់រងប្រភេទផ្សេងៗ។ នៅឆ្នាំ 2011 ក្រុមហ៊ុនធានារ៉ាប់រង បង់ប្រហែល $500 លានដុល្លារ នៅក្នុងប្រាក់ចំណូលពន្ធបុព្វលាភ ទៅលើគោលការណ៍យានយន្តនៅកាលីហ្វ័រញ៉ា។ ប្រាក់ចំណូលទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិកាទូទៅរបស់រដ្ឋ។

## សេចក្ដីស្នើច្បាប់

វិធានការនេះ អនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រងមួយផ្ដល់ការបញ្ចុះតម្លៃ "ការគ្រប់ដណ្ដប់ជាបន្ត" លើគោលការណ៍ធានារ៉ាប់រងយានយន្តចំពោះអតិថិជនថ្មី ដែលប្ដូរការគ្របដណ្ដប់របស់ខ្លួនមកពីអ្នកធានារ៉ាប់រងមួយផ្សេងទៀត។ ក្រោមវិធានការនេះ ការគ្របដណ្ដប់ធានារ៉ាប់រងមានន័យជាទូទៅថា ការគ្របដណ្ដប់ធានារ៉ាប់រងយានយន្តគ្មានការផ្អាកជាមួយអ្នកធានារ៉ាប់រងណាមួយក៏ដោយ។ ទោះបីជាយ៉ាងណា អ្នកប្រើប្រាស់ដែលមានរយៈកាល

# សំណើប្រជាមតិ 33 ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ តំលៃបុព្វលាភរ៉ាប់រងផ្អែកលើប្រវត្តិការរ៉ាប់រងរបស់អ្នកបើកបរ។ ច្បាប់ផ្ដើមប្រជាសិទ្ធិ។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** **(ត)**

កន្លងទៅនៅក្នុងការគ្របដណ្ដប់ នឹងនៅតែមានសិទ្ធិទទួលបានការបញ្ចុះតម្លៃនេះ ប្រសិនបើរយៈកាលកន្លងទៅ៖

- មិនច្រើនជាង ៩០ ថ្ងៃ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកដោយមូលហេតុណាមួយក៏ដោយ។
- ច្រើនជាង 18 ខែ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកដោយសារការបាត់បង់ការងារ ដែលបណ្ដាលមកពីការផ្អាកឲ្យឈប់ធ្វើការ ឬការអនុញ្ញាតឲ្យឈប់សម្រាកបណ្ដោះអាសន្ន ។
- បណ្ដាលមកពីសេវាកងទ័ពដែលកំពុងសកម្ម។

ដូចគ្នានេះដែរ កុមារដែលស្នាក់នៅជាមួយឪពុកម្ដាយក៏អាចមានគុណវុឌ្ឍិគ្រប់គ្រាន់ ក្នុងការទទួលបានការបញ្ចុះតម្លៃនេះដែរ ដោយផ្អែកលើសិទ្ធិទទួលបានរបស់ឪពុកម្ដាយរបស់ពួកគេ។

ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រង ជ្រើសរើសផ្ដល់ការបញ្ចុះតម្លៃបែបនេះនោះ ការបញ្ចុះតម្លៃនឹងត្រូវផ្ដល់តាមសមាមាត្រ។ ការបញ្ចុះតម្លៃ នឹងផ្អែកលើចំនួនឆ្នាំនៅក្នុងរយៈពេលប្រាំឆ្នាំភ្លាមៗ (រំលងជុំដល់ចំនួនទាំងមូល) ដែលអតិថិជនត្រូវបានធានារ៉ាប់រង។ ឧទាហរណ៍ ប្រសិនបើអតិថិជនអាចបង្ហាញឲ្យឃើញថា គាត់មានការគ្របដណ្ដប់រយៈពេលបីឆ្នាំ ក្នុងចំណោមប្រាំឆ្នាំមុននោះ អតិថិជននោះនឹងទទួលបាន ៦០ ភាគរយនៃការបញ្ចុះតម្លៃការគ្របដណ្ដប់បន្ត។

## ឥទ្ធិពលសារពើពន្ធ

វិធានការនេះ អាចបណ្ដាលឲ្យមានការផ្លាស់ប្ដូរចំនួនសរុបនៃបុព្វលាភធានារ៉ាប់រងយានយន្តសរុប ដែលរកបានដោយក្រុមហ៊ុនធានារ៉ាប់រងនៅរដ្ឋកាលីហ្វ័រញ៉ា និងចំនួនប្រាក់ចំណូលពន្ធបុព្វលាភដែលបានទទួលដោយរដ្ឋ។ ឧទាហរណ៍ ការណែនាំអំពីការបញ្ចុះតម្លៃការគ្របដណ្ដប់បន្តអាចកាត់បន្ថយចំនួនបុព្វលាភដែលបង់ដោយអ្នកដែលមានសិទ្ធិទទួលបានការបញ្ចុះតម្លៃ។ ទោះបីជាយ៉ាងណា ជាទូទៅចំនួននេះ នឹងបង្កើតបានដោយបុព្វលាភបន្ថែម ដែលបង់ដោយអ្នកដែលមិនមានសិទ្ធិទទួលបានការបញ្ចុះតម្លៃបែបនេះ។ ការប៉ះពាល់សរុបទៅលើប្រាក់ចំណូលពន្ធបុព្វលាភរដ្ឋដែលបណ្ដាលមកពីវិធានការនេះ នឹងប្រហែលជាមិនធំធេងទេ។



*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 33, សូមអានទំព័រ 94។*